ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០៧១/២៣ អអរ

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកោះកុង"

រសៀលថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកោះកុង»** ដែលមានវាគ្មិនចូលរួមគឺ៖

- **លោកជំទាវ មិថុនា ភូថង អភិបាល នៃគណៈអភិបាលខេត្តកោះកុង**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តកោះកុង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តកោះកុង ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តកោះកុង ជាខេត្តមួយស្ថិតនៅភាគនារតីនៃប្រទេសកម្ពុជា ដែលបែងចែកជា ក្រុង១ ស្រុក៦ ២៩ឃុំ-សង្កាត់ និង១១៩ភូមិ មានប្រជាពលរដ្ឋរស់នៅសរុប ១៤៧.៨៣១នាក់ ស្មើនឹង ៣៤.៥៦៨គ្រួសារ ក្នុងនោះប្រជាពលរដ្ឋប្រកបមុខរបរសំខាន់ទៅលើ វិស័យកសិកម្ម សេវាកម្ម ពាណិជ្ជកម្ម និងឧស្សាហកម្ម។

គិតត្រឹមឆ្នាំ២០២១ ចំណូលជាមធ្យមប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋម្នាក់គឺ ១.៧៤៦ដុល្លាអាមេរិក អត្រាភាពក្រីក្រថយចុះមកត្រឹម ៧,៣% និងទំហំសេដ្ឋកិច្ចទាំងមូលរបស់ខេត្តមានប្រមាណ ២៨២លានដុល្លា ស្មើនឹង ១,០៣នៃសេដ្ឋកិច្ចជាតិសរុប។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជាបន្តបន្ទាប់ ជូនប្រជាពលរដ្ឋក្នុងខេត្ត ដោយក្នុងនោះ ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បានចំនួន ១៣.០២៣គ្រួសារ ចំណាយថវិកាសរុប ៥១.៦៣១.៦៧៤.០០០រៀល, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួន២.៣៣៩នាក់ ចំណាយថវិកា ៧៧៣.៨៤០.០០០រៀល និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដោយបានបើកផ្ទាល់សរុប ១.៩៥៤គ្រួសារ ស្មើនឹងថវិកា ២៨៤.៤៨០.២០០រៀល និងបានបើកតាមបញ្ជរវីងចំនួន ១.៨៤៦គ្រួសារ ស្មើនឹងថវិកា ២៦៩.២០៧.៨០០រៀល។
- **វិស័យកសិកម្ម៖** ការអនុវត្តទៅលើដំណាំស្រូវចំនួន ៥០.៤៤៣ហិកតា ទទួលបានទិន្នផលសរុបប្រមាណ ១៣៦.១៩៦តោន សម្រាប់ប្រើប្រាស់ក្នុងស្រុក និងបានអនុវត្តទៅលើដំណាំឧស្សាហកម្ម ដំណាំរួមផ្សំ ដំណាំអចិន្ត្រៃយ៍(ស្វាយចន្ទី ធុរេន ដំណាំហូបផ្លែមួយចំនួនទៀត) ដែលទទួលបានទិន្នផលសម្រាប់នាំចេញសរុបចំនួន ៣៧.៣២០តោន។ ក្រៅពីនោះ ប្រជាពលរដ្ឋ បានបង្កើតជាកសិដ្ឋានចិញ្ចឹមសត្វ ការនេសាទជាដើម ដើម្បីផ្គត់ផ្គង់ជីវភាពបន្ថែម លើសពីនេះ រដ្ឋបាលខេត្តក៏បង្កើតឱ្យមានជាសមាគមកែច្នៃផលិតផល(៣កន្លែង) សហគមន៍នេសាទ(១០សហគមន៍) និងសហគមន៍កសិកម្ម(៣សហគមន៍) ក្នុងន័យលើកស្ទួយផលិតផលក្នុងខេត្ត ស្វែងរកទីផ្សារ និងជានានូវតម្លៃជូនដល់ប្រជាពលរដ្ឋ។
- **វិស័យទេសចរណ៍៖** ជាខេត្តមួយសម្បូរទៅដោយធនធានធម្មជាតិ ដែលជាសក្តានុពលទាក់ទាញភ្ញៀវទេសចរឱ្យមានការកើនឡើងជាបន្តបន្ទាប់ដូចជា ព្រៃកោងកាង ទឹកធ្លាក់ តំបន់អេកូទេសចរណ៍ធម្មជាតិ តំបន់ឆ្នេរ ផ្កាថ្ម និងតំបន់កោះមួយចំនួនទៀត ក្នុងនោះ តំបន់អេកូទេសចរណ៍ធម្មជាតិព្រៃកោងកាង ទំហំសរុប ៦២.០០០ហិកតា ឆ្នេរសមុទ្រ មានប្រវែងប្រមាណ២១៥គីឡូម៉ែត្រ ដែលបានជាប់ជាសមាជិកក្លឹបឆ្នេរសមុទ្រស្អាតបំផុតនៅលើពិភពលោក និងត្រូវបានប្រសិទ្ធនាមថា "**តារាះនាទិសនិរតី**" ព្រមទាំងទទួលបានជ័យលាភី ក្នុងការប្រឡងប្រជែងឆ្នេរស្អាតផងដែរ។

ជាក់ស្តែង ក្នុងឆ្នាំ២០២២ ភ្ញៀវទេចរមកកំសាន្តនៅខេត្តកោះកុងមានចំនួន ៤៣៥.៩០៣នាក់ ក្នុងនោះភ្ញៀវជាតិចំនួន ៤៣០.០៤២នាក់ និងភ្ញៀវអន្តរជាតិចំនួន ៥.៨៦១នាក់ បើធៀបនឹងឆ្នាំ២០២១ មានការកើនឡើងចំនួន ២០៦.៦៥៦នាក់ ស្មើនឹង ៩១%។

- **ការផ្តល់សេវាសាធារណៈ៖** រដ្ឋបាលខេត្ត បានជំរុញ លើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ តាមរយៈយន្តការច្រកចេញ-ចូលតែមួយថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ សរុបមានចំនួន ៣៧កន្លែង ហើយអង្គភាពច្រកចេញ-ចូលតែមួយនៃរដ្ឋបាលខេត្ត ដោយក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ បានផ្តល់សេវាជូនប្រជាពលរដ្ឋ សរុបចំនួន២០.៧៧៥សេវា ទទួលបានថវិកាសរុបបានចំនួន៣.៣២៧.៩៩៦.១៥២រៀល។
- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** ដោយមានការសហការជាមួយមន្ទីរសាធារណការ និងមន្ទីរអភិវឌ្ឍន៍ជនបទ រដ្ឋបាលខេត្ត បានខិតខំជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្ត ដោយសម្រេចបាននូវការកសាង ថែរក្សា និងជួសជុលជាបន្តបន្ទាប់ និងជាប្រចាំទៅលើផ្លូវថ្នល់ ប្រឡាយ ទំនប់ទឹក ប្រព័ន្ធលូរំដោះទឹក ស្ពាន កំពង់ផែ បង្គន់អនាម័យ អណ្តូងស្នប់ជាដើម ក្នុងន័យលើកស្ទួយសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្ត បានដាក់ចេញនូវទិសដៅការងារសំខាន់ៗ ដើម្បីបន្តអភិវឌ្ឍន៍ខេត្ត ដែលរួមមាន៖

- បន្តពង្រឹងការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព
- ជំរុញការផ្តល់សេវារដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ ឱ្យកាន់តែមានគុណភាព តម្លាភាព និងប្រសិទ្ធភាព
- បន្តខិតខំបណ្តុះបណ្តាលធនធានមនុស្សឱ្យបានកាន់តែច្រើន
- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចខេត្ត ឱ្យសម្រេចបានកំណើនខ្ពស់ ស្របតាមគោលនយោបាយកាត់បន្ថយអត្រាភាពក្រីក្ររបស់រាជរដ្ឋាភិបាល
- ខិតខំអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់គ្រប់ប្រភេទទាំងផ្លូវទីប្រជុំជន និងផ្លូវជនបទ
- គ្រប់គ្រង និងអភិវឌ្ឍគោលដៅទេសចរណ៍សំខាន់ៗ កែលម្អសេវាទេសចរណ៍ និងបង្កើនផលិតផលទេសចរណ៍ អនុវត្តទិសដៅ នៃការអភិវឌ្ឍបៃតង ជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត រមនីយដ្ឋានស្អាត ទីក្រុងបៃតង បំផុសចលនាការបង្កើនអនាម័យ ការដាំដើមឈើជាដើម
- ខិតខំដោះស្រាយបញ្ហាលំបាកនានារបស់ប្រជាពលរដ្ឋ។

## IV. សម្គាល់

រដ្ឋបាលខេត្ត បានខិតខំប្រឹងប្រែងអនុវត្តនូវគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដោយរក្សាបាននូវសុខសុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសផ្តល់នូវទំនុកចិត្តដល់ភ្ញៀវទេសចរ ក៏ដូចជាអ្នកវិនិយោគផងដែរ។ ជាមួយគ្នានេះ រដ្ឋបាលខេត្តក៏បាននឹងជំរុញការកែលម្អសោភណភាពទីក្រុង រៀបចំឱ្យមានទីលានកែច្នៃ និងចាក់សំរាម ការសាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសគឺការសាងសង់ផ្លូវជាតិលេខ១០ ដែលលាតសន្ធឹងពីខេត្តកោះកុង ពោធិ៍សាត់ បាត់ដំបង ដោយចេញពីទីរួមខេត្តកោះកុង កាត់តាមផ្លូវទំនប់វារីអគ្គិសនីឬស្សីជ្រុំ និងទំនប់វារីអគ្គិសនីតាតៃ មកអូរសោម វាលវែង និងសំឡូត មានប្រវែង១៩៧,៣៧គីឡូម៉ែត្រ ទទឹងផ្លូវ ៩ម៉ែត្រ ក្រាលកៅស៊ូពីរស្រទាប់ (DBST) កំពុងបន្តសាងសង់ និងសម្រេចបាន៦៩,២៨%រួចមកហើយ៕

ថ្ងៃអង្គារ ២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣